ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៣៦២១.....អពដ

ថ្ងៃសុក្រ ១៥ រោច ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ២០១៨

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ និងប្រកាសលេខ ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនដំណឹងដល់សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ មេត្តាជ្រាបអំពីកាតព្វកិច្ចនៃការដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់សម្រាប់ឆ្នាំ២០១៨ ដូចខាងក្រោម÷

១. អ្នកជាប់ពន្ធទាំងអស់ រួមទាំងអ្នកជាប់ពន្ធដែលមិនទាន់បានធ្វើបច្ចុប្បន្នភាព និងអ្នកជាប់ពន្ធដែលបានធ្វើបច្ចុប្បន្នភាពរួចរាល់ហើយ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨។

២. អ្នកជាប់ពន្ធធំអាចទៅបង់ពន្ធប៉ាតង់នៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធតូចអាចទៅបង់ពន្ធប៉ាតង់នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ដែលសហគ្រាសស្ថិតនៅ ឬនៅតាមសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ឬសាខាធនាគារកាណាឌីយ៉ា ក.អ ឬសាខាធនាគារវឌ្ឍនៈ ឬសាខាធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ឬសាខាធនាគារអេ អិន ហ្សេត រ៉ូយ៉ាល់ ទូទាំងប្រទេស។

៣. ចំពោះអ្នកជាប់ពន្ធដែលបានធ្វើបច្ចុប្បន្នភាព ដែលមានប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ រួចហើយមិនតម្រូវឱ្យបំពេញលិខិតប្រកាសស្នើសុំបង់ពន្ធប៉ាតង់ទៀតទេ។ ប័ណ្ណប៉ាតង់ឆ្នាំ២០១៨ នឹងត្រូវបានបោះពុម្ពជូនអ្នកជាប់ពន្ធភ្លាមៗដោយមិនយកកម្រៃសេវា ប្រសិនបើអ្នកជាប់ពន្ធទៅបោះពុម្ពនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារខេត្ត-ខណ្ឌ ដែលសហគ្រាសស្ថិតនៅ។ ក្នុងករណីអ្នកជាប់ពន្ធជ្រើសរើសការបោះពុម្ពនៅសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ឬសាខាធនាគារកាណាឌីយ៉ា ក.អ ឬសាខាធនាគារវឌ្ឍនៈ ឬសាខាធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ឬសាខាធនាគារអេ អិន ហ្សេត រ៉ូយ៉ាល់ ត្រូវបង់កម្រៃសេវាជូនធនាគារចំនួន ៤ ០០០ រៀល/ប័ណ្ណ។

៤. អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយនៅក្នុងរាជធានី-ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។ អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្ម នៅរាជធានី-ខេត្តផ្សេងគ្នា អាចបង់ពន្ធប៉ាតង់រួមគ្នានៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារខេត្ត-ខណ្ឌ ឬសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ឬសាខាធនាគារកាណាឌីយ៉ា ក.អ ឬសាខាធនាគារវឌ្ឍនៈ ឬសាខាធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ឬសាខាធនាគារអេ អិន ហ្សេត រ៉ូយ៉ាល់ ប៉ុន្តែត្រូវញែកប្រាក់ពន្ធទៅតាមគណនីរបស់សាខាពន្ធដារខេត្ត-ខណ្ឌ ឬ



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ដែលអាជីវកម្មនោះស្ថិតនៅ។ ក្នុងករណីអ្នកជាប់ពន្ធជ្រើសរើសការបោះពុម្ពប័ណ្ណប៉ាតង់សាខា ឃ្លាំង រោងចក្រ រោងជាង នៅសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ឬសាខាធនាគារកាណាឌីយ៉ា ក.អ ឬសាខាធនាគារវឌ្ឍនៈ ឬសាខាធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ឬសាខាធនាគារ អេ អិន ហ្សេត រ៉ូយ៉ាល់ ត្រូវបង់កម្រៃសេវាជូនធនាគារដូចបានកំណត់នៅចំណុចទី៣ខាងលើ។

៥. ចំពោះអ្នកជាប់ពន្ធដែលមិនទាន់ធ្វើបច្ចុប្បន្នភាពការចុះបញ្ជីពន្ធដារ ត្រូវបំពេញលិខិតប្រកាសស្នើសុំបង់ពន្ធប៉ាតង់តាមទម្រង់ បព ០០៨/ Form PR 008 បន្ទាប់មកត្រូវទៅធ្វើបច្ចុប្បន្នភាពឬ ចុះបញ្ជីពន្ធដារនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខេត្ត-ខណ្ឌ ឬក្រុមការងារចុះបញ្ជីពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារនៅជាន់ទី០៦ នៃអគារសាលាជាតិពន្ធដារ ទើបអាចទទួលបានប័ណ្ណប៉ាតង់ឆ្នាំ២០១៨នេះ។

៦. អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើនប្រភេទ ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។ សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។

៧. ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចតទៅ÷

ក- **អ្នកជាប់ពន្ធតូច** ត្រូវបង់ពន្ធប៉ាតង់ចំនួន ៤០០ ០០០ រៀល។

ខ- **អ្នកជាប់ពន្ធមធ្យម** ដែលមានក្នុងបញ្ជីពន្ធដារបច្ចុប្បន្នត្រូវបង់ពន្ធប៉ាតង់ចំនួន ១ ២០០ ០០០ រៀល។

គ- **អ្នកជាប់ពន្ធធំ** ដែលមាននៅក្នុងបញ្ជីពន្ធដារបច្ចុប្បន្នដែលមាន÷

- ផលរបរ ១០ ០០០ ០០០ ០០០ រៀល ឬតិចជាង ត្រូវបង់ពន្ធប៉ាតង់ចំនួន ៣ ០០០ ០០០ រៀល
- ផលរបរលើសពី ១០ ០០០ ០០០ ០០០ រៀល ត្រូវបង់ពន្ធប៉ាតង់ចំនួន ៥ ០០០ ០០០ រៀល។

អ្នកជាប់ពន្ធធំដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយដែលស្ថិតនៅតាមរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ចំនួន ៣ ០០០ ០០០ រៀល។

៨. អ្នកជាប់ពន្ធត្រូវដាក់តាំងបង្ហាញប័ណ្ណប៉ាតង់ដែលមានសុពលភាព នៅទីតាំងប្រកបអាជីវកម្មរបស់ខ្លួន ហើយប័ណ្ណប៉ាតង់មានតម្លៃតែចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់តែប៉ុណ្ណោះ។ អគ្គនាយកដ្ឋានពន្ធដារមានវិធីគ្រប់គ្រងនិងបោះពុម្ពប័ណ្ណប៉ាតង់តាមប្រព័ន្ធអេឡិកត្រូនិក ដែលមិនអាចក្លែងបន្លំបានឡើយ។

៩. អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់ប្រាក់ពន្ធឱ្យបានត្រឹមត្រូវទៅតាមពេលវេលា ដែលច្បាប់បានកំណត់។ ក្នុងករណីមានការយឺតយ៉ាវមិនបានបង់ពន្ធឱ្យទាន់ពេលវេលា ឬព្យាយាមបន្លំផលរបរ ដើម្បីគេចវេះពីការបង់ប្រាក់ពន្ធប៉ាតង់ ឬមានការក្លែងបន្លំប័ណ្ណប៉ាតង់ នឹងត្រូវទទួលរងនូវទោសទណ្ឌដូចមានចែងក្នុងច្បាប់ស្ដីពីសារពើពន្ធ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមនិងជឿជាក់ថា សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងនេះ ជាក់ជាពុំខាន។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋាន ពន្ធដារ

**គង់ វិបុល**